# ស្ទីវ ចប
# Steve Jobs



លោកវ័លធី អ៊ីសាកសុន

Walter Isaacson

# ស្ទីវ ចប

## តើសៀវភៅនេះនិយាយពីអ្វី ?

សៀវភៅនេះនិយាយពីជីវប្រវត្តិរបស់ស្ទីវចប ដែលជាអតីតសហស្ថាបនិកក្រុមហ៊ុនអេបផល និងទូរស័ព្ទ អាយហ្វូនដែលយើងប្រើប្រាស់ប្រចាំថ្ងៃ។ សៀវភៅនេះរៀបរាប់តាំងពីកុមារភាពរបស់លោក រួមទាំងហេតុអ្វីបានជាគាត់មានគំនិតប្លែកខុសពីគេ។ លើសពីនេះ សៀវភៅនេះក៏និយាយពីចរិតការងារ និងចរិតជីវិតឯកជនរបស់គាត់ផងដែរ និងប្រាប់ពីមូលហេតុថាហេតុអ្វីបានជាគេបណ្ដេញគាត់ពី ក្រុមហ៊ុនគាត់ជាអ្នកបង្កើត ហើយម៉េចបានជាគាត់អាចវិលត្រឡប់មកអេបផលវិញបាន ?

## តើអ្នកនិពន្ធជានរណា ?

លោកវ៉លធឺ អ៊ីសាកសុន (Walter Isaacson) គឺជាអ្នកនិពន្ធពីប្រវត្តិមនុស្សល្បីល្បាញក្នុងលោកជាច្រើន ពីព្រោះគាត់មិនត្រឹមតែជាអ្នកនិពន្ធប៉ុណ្ណោះ ប៉ុន្តែគាត់ក៏ជាប្រវត្តិរូបវិទូម្នាក់ផងដែរ។ សៀវភៅដែលលក់ដាច់បំផុតរបស់គាត់មានដូចជាសៀវភៅពីជីវប្រវត្តិរបស់ អាល់ប៊ឺត អែនស្តែន និងប៊ិនចាមីន ហ្វ្រេងលីន ជាដើម។ លើសពីនេះ គាត់ក៏ជានាយកប្រតិបត្តិ និងប្រធានក្រុមប្រឹក្សាភិបាលរបស់បណ្ដាញសារ ព័ត៌មានស៊ីអេនអេន (CNN news network) ទៀតផង។

# សេចក្តីប្រកាស

១. សៀវភៅសង្ខេប “ស្ទីវ ចប” មួយក្បាលនេះគឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុន BOOKEYOND CO., LTD ដែលផ្តល់សេវាកម្មអេបទូរសព្ទដៃសង្ខេបសៀវភៅឈ្មោះថា bookeyond ត្បិតសៀវភៅសង្ខេបនេះគឺជាការសង្ខេបរៀបរៀងដើម ដោយក្រុមការងារអេប bookeyond ផ្ទាល់ និងមិនមែនជាការបកប្រែទាំងដុលចេញពីប្រភពបរទេសតែមួយណាឡើយ។

២. សៀវភៅសង្ខេប “ស្ទីវ ចប” មួយក្បាលនេះត្រូវបាន អនុញ្ញាតឲ្យចែករំលែកបន្តគ្នាបាន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ និងមិនអនុញ្ញាតឲ្យយកទៅធ្វើអាជីវកម្មបន្តគ្រប់រូបភាព ដោយគ្មានការអនុញ្ញាតពីក្រុមហ៊ុន BOOKEYOND CO., LTD ឡើយ។

# បញ្ហា (គំនិតស្នូល) ក្នុងសៀវភៅ

១. ស្ទីវចបមានគំនិតស្រឡាញ់ការឌីស្សាញ និងវិស្វកម្មកុំព្យូទ័រ ដោយសារឪពុកចិញ្ចឹម និងមិត្តល្អរបស់គាត់

២. សមាធិការងារខ្ពស់ និងញ្ញាណដឹងពីសម្រស់របស់ចបគឺបានមកពីការប្រើប្រាស់ ថ្នាំមើមមាយអេលអេសឌី (LSD) និងការសមាធិខាងព្រលឹងវិញ្ញាណ

៣. ក្រុមហ៊ុនអេបផលកុំព្យូទ័របង្កើតឡើងក្រោមគំនិតច្នៃប្រតិដ្ឋរបស់ស្ទីវវ៉ូស្នៀក ហើយឈ្មោះ ថា អេបផល ចបគាត់នឹកឃើញក្រោយពីគាត់បានទៅលេងចំការអេបផល ឬចំការផ្លែប៉ម

៤. ភាពនិយមភាពល្អឥតខ្ចោះ ឬសុក្រិតភាពពេកបានធ្វើឲ្យចបមានចរិកលក្ខណៈ គ្រប់គ្រងត្រួតត្រាលើបុគ្គលិកជ្រុល និងក្លាយជាមនុស្សឆេវឆាវឃោរឃៅ

៥. ចរិតលក្ខណៈចូលចិត្តភាពសុក្រិត្យនិយម និងនិយមភាពល្អឥតខ្ចោះ បានធ្វើឲ្យគាត់ផលិតកុំព្យូទ័រប្រេនម៉ាក់ស៊ីនថូសបានលក់យ៉ាងជោគជ័យ តែក៏បានធ្វើឲ្យត្រូវគេបណ្ដេញចេញពីក្រុមហ៊ុនខ្លួនឯងដែរ

៦. ក្រោយពីចេញពីអេបផល ចបមកបង្កើតក្រុមហ៊ុននិក និងទិញក្រុមហ៊ុនពិសារ។ តែសុទ្ធតែបរាជ័យលើរឿងបង្កើតកម្មវិធីកំព្យូទ័រ និងគ្រឿងកំព្យូទ័រ តែត្រូវប៉ាន់នឹងភាពយន្តតុក្កតាទៅវិញ

៧. ចបបានវិលមករកគ្រួសារបង្កើតគាត់វិញ និងបង្កើតគ្រួសារផ្ទាល់ខ្លួនមួយ និងផ្សះផ្សារជាមួយ កូនស្រីដែលគាត់បានបោះបង់ចោលពីមុន

៨. ការធ្លាក់ខ្លួនរបស់អេបផលបង្ខំឲ្យស្ទីវចបត្រឡប់មកជួយអេបផលវិញ។ តែចបបាន ប្រមូលអំណាចខ្លួនយកមកវិញ និងបណ្ដេញចោលក្រុមប្រឹក្សាភិបាលចាស់ៗ ដើម្បីគាត់បានធ្វើការងារដោយស្រួល

៩. ចបបង្កើតបានអាយម៉ាក់ (iMac) ក្រោយពីបានជួបដៃគូអ្នកឌីស្សាញពោរពេញ ទេពកោសល្យ និងការស្រមើស្រមៃម្នាក់

១០. អេបផលបានបង្កើតអាយផត អាយហ្វូន និងអាយផេតឡើង ដើម្បីចង់គ្រប់គ្រង ឧបករណ៍ឌីជីថលទាំងឡាយ

១១. ចរិតត្រួតត្រាគ្រប់គ្រងជារបស់ខ្លួនឯងធ្វើឲ្យចបបង្កើតការប្តឹងប្តល់អ្នកជុំវិញ ដែលអាចផលិតបានស្រដៀងខ្លួន

១២. ចបស្លាប់មុនការគ្រោងទុក ដោយសារតែចចេសមិនស្តាប់ និងចង់ធ្វើអ្វីដែលប្លែកខុសពីភាពជដែលៗ

# អេបសង្ខេបសៀវភៅជាភាសាខ្មែរដំបូងគេបង្អស់នៅកម្ពុជា (អាន+ស្តាប់)



1. ទាញយកអេប bookeyond ភ្លាម នឹងបានទទួល **10$** ក្នុងអេបដោយស្វ័យប្រវត្តិ សម្រាប់ទិញសៀវភៅក្នុងអេបភ្លាម

2. Join តេឡេក្រាមឆាណែល bookeyond ភ្លាម នឹងបានកាដូ **5$** ក្នុងអេប បន្ថែមទៀត (ប៉ុន្តែត្រូវទាក់ទងមកក្រុមការងារដើម្បីទទួលបានកាដូ5$ក្នុងអេប)

ទាញយកអេបឥឡូវនេះ

**Join Telegram**

“ជម្នះភាពដដែលៗ” គឺជាបុព្វហេតុរបស់យើង។
ដោយសារបុព្វហេតុនេះ យើងបង្កើតអេប bookeyond ឡើង ដើម្បីបដិវត្តរបៀបយើងរៀន។
យើងមិនរៀនដូចមុនឡើយ។ យើងអាចរៀនពេលហាត់ប្រាណ បោកខោអាវ ធ្វើដំណើរ ស្ទះចរាចរណ៍...

# ១
# ស្ទីវចបមានគំនិតស្រឡាញ់ការឌីស្សាញ និងវិស្វកម្មកុំព្យូទ័រដោយសារឪពុកចិញ្ចឹម និងមិត្តល្អរបស់គាត់

ស្ទីវចប (Steve Jobs) កើតនៅថ្ងៃទី២៤ កុម្ភៈ ១៩៥៥។ ស្ទីវចបមានឪពុកម្ដាយចិញ្ចឹមឈ្មោះថា លោក ផូលចប និងអ្នកស្រីខ្លារ៉ាចប។ ពួកគាត់ទាំងពីរនាក់នេះរស់នៅក្នុងសង្កាត់ស៊ីលីកូន វ៉លលី (Silicon Valley) សហរដ្ឋអាមេរិក។ តាមពិតទៅ ស្ទីវចបត្រូវបានឪពុកម្ដាយបង្កើតគាត់បោះបង់ចោលតាំងពីគាត់ នៅជាទារកមកម្ល៉េះ។ រឿងហេតុដែលបង្កឲ្យមានការបោះបង់កូនចោលបែបនេះ គឺដោយសារតែ មានការបង្ខិតបង្ខំពីគ្រួសារខាងម្ដាយបង្កើតគាត់។ ស្ថិតនៅក្នុងគ្រួសារគ្រីស្ដបរិស័ទកាតូលិកដ៏តឹងរ៉ឹង មួយ ម្ដាយបង្កើតចបឈ្មោះថា ចូអាន សាយបល (Joanne Schieble) ត្រូវបានគ្រួសារគាត់ហាមមិន ឲ្យយក ឪពុកបង្កើតចបឈ្មោះអាប់ឌុលហ្វាតា ចាន់ដាលី (Abdulfattah Jandali) ទេ មូលហេតុគឺដោយសារតែ លោកកាន់សាសនាអ៊ីស្លាម។

ឪពុកចិញ្ចឹមគាត់លោកផូលចប គឺជាជាងបច្ចេកទេសវិស្វកម្មរថយន្ត ហើយគាត់គឺជាអ្នកដែលបាន ណែនាំចបឲ្យស្គាល់ពីពិភពវិស្វកម្ម និងឌី្ស◌ាសាញរចនា។ លោកផូលបានព្យាយាមបណ្ដុះបណ្ដាល និងផ្ទេរជំនាញជាង ឡានឲ្យស្ទីវចបតាំងពីក្មេងមកម្ល៉េះ។ ស្ទីវចបធ្លាប់បានរម្លឹកថា គាត់ពិតជាចាប់អារម្មណ៍ស្នាដៃហត្ថកម្ម ឪពុកគាត់ខ្លាំងណាស់។ ឧទាហរណ៍ បើគ្រួសារគាត់ត្រូវការទូមួយ ឪពុកចិញ្ចឹមគាត់លោកផូ

លហ្នឹង នឹងធ្វើមួយដោយខ្លួនឯង ហើយប្រើស្ទីវចបឲ្យជួយកិច្ចការនោះ ដែរដើម្បីឲ្យគាត់ចេះ។

គំនិតឱស្សាញបែបសាមញ្ញស្អាតសណ្ដាប់ធ្នាប់ និងប្រណិតថ្លៃថ្នូរបាន ដក់ជាប់នៅក្នុងគំនិតគាត់ តាំងពីគាត់នៅក្មេង ដោយសារតែគាត់ធ្លាប់ រស់នៅក្នុងផ្ទះឪពុកម្ដាយចិញ្ចឹមគាត់ដែលមាន លក្ខណៈសាមញ្ញ ដែល មានកម្រាល ជញ្ជាំង និងពិដានភាគច្រើនធ្វើពីកញ្ចក់ និងបើកវាល ទូលាយ មិនស្មុគស្មាះ រញ៉េរញ៉ៃ តាំងពីពេលគាត់នៅតូច។ ផ្ទះគ្រួសារ នោះមិនថ្លៃទេ ប៉ុន្តែស្អាតសាមញ្ញ។ ផ្ទះប្រភេទនោះមានឈ្មោះថា ផ្ទះ អាយឃ្លើរ (Eichler house) ដែលយកតាមឈ្មោះអ្នករចនាប្លង់ អចលនទ្រព្យអាមេរិកកាំងឈ្មោះថា ចូសែហ្វ អាយឃ្លើរ (Joseph Eichler)។

ស្ទីវចបបានរៀន និងស្វែងយល់បានច្រើនពីកុំព្យូទ័រពីមិត្តភក្ដិវិទ្យាល័យ គាត់ម្នាក់ដែលមានឈ្មោះថា ស្ទីវវ៉ូស្នៀក (Steve Wozniak)។ តាម ពិតទៅ ស្ទីវវ៉ូស្នៀកចេះ និងមានទេពកោសល្យខាងបច្ចេកទេស កុំព្យូទ័រ តាំងពីមុនស្គាល់ស្ទីវចបមកម៉្លេះ។ ពួកគាត់ទាំងពីរនាក់មានមិត្តភាព ស្អិតរមួតនឹងគ្នាណាស់ បើទោះជា ស្ទីវវ៉ូស្នៀកចាស់ជាងស្ទីវចប ៥ឆ្នាំក៏ ដោយ។

ពួកគាត់ទាំងពីរនេះចូលចិត្តលេងសើច និងចូលចិត្តលេងបោកបញ្ឆោត គ្នាណាស់ ប៉ុន្តែក៏ចូលចិត្តរុករក ស្រាវជ្រាវឧបករណ៍អេឡិចត្រូនិចខ្លាំង ណាស់ ដើម្បីរកមើលថាតើពួកគេអាចបង្កើតអ្វីបាន។ នៅឆ្នាំ ១៩៧១

ពួកគាត់ទាំងពីរក៏បង្កើតឧបករណ៍ដំបូងម៉្យាងដែលអាចឲ្យអ្នកប្រើប្រាស់តេទូរស័ព្ទហៅទៅ មនុស្សដែលនៅឆ្ងាយបានដោយឥតគិតថ្លៃ។ ឧបករណ៍នោះ ពួកគាត់ឲ្យឈ្មោះថា “ប្រអប់ខៀវ ( Blue Box )”។ អ្នកបង្កើតឱស្សាញគឺលោកស្ទីវវ៉ូស្នៀក។ ហើយអ្នកធ្វើឲ្យគំនិតច្នៃប្រតិដ្ឋរបស់ពួកគាត់ក្លាយ ទៅជាអាជីវកម្មគឺស្ទីវចប។ កាលនោះចបទិញវត្ថុធាតុដើមអស់ ៤០ដុល្លារ ហើយលក់ឧបករណ៍ប្រអប់ ខៀវនោះក្នុងតម្លៃ ១៥០ដុល្លារ។ អ្នកទាំងពីរលក់ឧបករណ៍បានជិត ១០០ឯកតា។ ទឹកលុយដែលពួក គាត់ទាំងពីរទទួលបានបានធ្វើឲ្យស្ទីវវ៉ូស្នៀកកាន់តែខំប្រឹងអភិវឌ្ឍជំនាញវិស្វកម្មកុំព្យូទ័ររបស់គាត់ រីឯ ស្ទីវចបវិញកាន់តែមានទឹកចិត្តមានទស្សនៈកាន់តែឆ្ពោះទៅមុខថែមទៀត។ ទីបំផុត ពួកគាត់ទាំងពីរនាក់ ក៏បានសម្រេចចិត្តសហការបង្កើតក្រុមហ៊ុន អេបផល ( Apple ) ឡើង នៅថ្ងៃទី ០១ មេសា ១៩៧៦។

# ២

# សមាធិការងារខ្ពស់ និងញាណដឹងពីសម្រស់របស់ចបគឺបានមកពីការប្រើប្រាស់ ថ្នាំមមើមមាយអេលអេសឌី (LSD) និងការសមាធិខាងព្រលឹងវិញ្ញាណ

ស្ទីវចបធ្លាប់បានលើកឡើងថាដើមហេតុដែលធ្វើឲ្យលោកមានញាណដឹងពីសម្រស់ ដឹងថាអ្វីស្អាត ឬមិនស្អាត និងដែលធ្វើឲ្យគាត់មានសមាធិការងារខ្ពស់ គឺដោយសារតែលោកបានភ្លក់បទពិសោធន៍ ប្រើប្រាស់ថ្នាំមមើលមហាយអេលអេសឌី (LSD) និងការហ្វឹកហាត់ខាងព្រលឹងវិញ្ញាណ (spirituality)។

ចបបានចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យរីឌ (Reed College) នៅក្នុងរដ្ឋអូរីហ្គននៅឆ្នាំ ១៩៧២។ សាលានេះគឺជាសាលារៀនឯកជនដែលផ្ដោតខាងសិល្បៈសេរី។ នៅសាលារៀននេះហើយដែលស្ទីវចបបានងប់ងល់មែនទែនទៅនឹងការធ្វើសមាធិខាងព្រលឹងវិញ្ញាណ និងសាកល្បងប្រើថ្នាំមមើមមាយ អេលអេសឌីជាមួយមិតភ័ក្តិ។

ចបមានអារម្មណ៍ថាការប្រើប្រាស់ថ្នាំមមើលមមាយបានជួយពង្រឹងវិញ្ញាណគាត់ឲ្យកាន់តែដឹងថា អ្វីសំខាន់បំផុតក្នុងជីវិតគាត់ និងបង្ហាញគាត់ពីអ្វីដែលគាត់មិនដែលធ្លាប់ឃើញពីមុនមក។ តាមរយៈ បទពិសោធន៍មមើលមមាយដោយសារថ្នាំ និងការសមាធិខាងព្រលឹងវិញ្ញាណ គាត់យល់ការពិតសម្រាប់ ខ្លួនគាត់ថា ការបង្កើតអ្វីដែលអស្ចារ្យៗគឺជាកិច្ចការសំខាន់ជាងកិច្ចការណាៗទាំងអស់ក្នុងជីវិតលោក។

កាលណោះគាត់បានទៅប្រទេសឥណ្ឌា ៧ខែ ដើម្បីស្វែងយល់ពីខាងព្រលឹងវិញ្ញាណក្នុងលិទ្ធិហ្សិន (Zen) នៃព្រះពុទ្ធសាសនានិកាយមហាយាន។ លិទ្ធិហ្សិនបានជះឥទ្ធិលយ៉ាងខ្លាំងដល់បុគ្គលិកលក្ខណៈ របស់ចប និងវិធីសាស្រ្តបង្កើតសម្រស់ល្អប្រណិតដោយប្រើភាពសាមញ្ញបំផុត និងបានណែនាំឲ្យលោក ស្គាល់ពីអំណាចរបស់អព្ភន្តរញាណ។ អព្ភន្តរញាណគឺជាការដឹងដោយអារម្មណ៍ជាអ្នកប្រាប់។ និយាយម្យ៉ាងទៀត គាត់បានដឹងថាអារម្មណ៍អាចប្រាប់ឲ្យមនុស្សយើងដឹងពីអ្វីមួយធុតខ្លាំងមែនទែន។

ការប្រើថ្នាំមើលមមាយអេលអេសឌី និងការសមាធិខាងព្រលឹងវិញ្ញាណបានធ្វើឲ្យគាត់មានសមត្ថភាព ពិសេសមួយដែលបុគ្គលិកគាត់ម្នាក់ហៅថា សមត្ថភាពកាឡៃការពិត (reality distortion field)។ បើគាត់ សម្រេចចិត្តធ្វើអ្វីមួយឲ្យកើតឡើងហើយ មនុស្សនៅជុំវិញខ្លួនគាត់ ពេលស្តាប់លឺគាត់និយាយ ពេលស្តាប់គាត់បង្ហាញពីរបស់មួយនោះ ពួកគេនឹងជឿថារឿងនោះនឹងក្លាយទៅជាការពិត និងមើល ឃើញរឿងនោះដូចជាការពិតអញ្ចឹង។ ពោលគឺគាត់អាចបត់បែនការពិតទៅតាមចិត្តគាត់បាន។

ស្ទីវចបតែងតែសង្កត់ធ្ងន់ជានិច្ចទៅលើភាពស្អាតសណ្តាប់ធ្នាប់ និងភាពសាមញ្ញ រាល់ពេលដែល ឪស្សាញរចនារាល់ផលិតផលអេបផលទាំងអស់។ ការស្រឡាញ់និងទាមទារចង់បានសោភ័ណភាព ស្អាតមិនស្មុគស្មាញនេះគឺដោយសារតែគាត់ស្រឡាញ់ចូលចិត្តសិល្បៈ ដែលលោកធ្លាប់បានរៀននៅ មហាវិទ្យាល័យរីឌ។ កាលនោះ បើទោះជាគាត់បាន

បោះបង់ចោលមហាវិទ្យាល័យនោះក៏ដោយ ក៏គ្រូនៅ តែអនុញ្ញាតឲ្យគាត់ចូលរៀនបន្ត។ ប៉ុន្តែគាត់រៀនតែមុខវិជ្ជាណាដែលត្រូវនឹងក្ដីបំណងគាត់តែប៉ុណ្ណោះ។ មុខវិជ្ជាដែលត្រូវនឹងចិត្តគាត់មួយនោះគឺ ថ្នាក់អក្សរផ្ចង់។ ដោយសារបានរៀនថ្នាក់នេះហើយ ទើបគាត់ មានជំនាញឌីស្សាញផ្ទៃអេក្រង់សម្រាប់អ្នកប្រើប្រាស់របស់កុំព្យូទ័រម៉ាក់ (Mac)។

# ៣
# ក្រុមហ៊ុនអេបផលកុំព្យូទ័របង្កើតឡើងក្រោមគំនិតច្នៃប្រតិដ្ឋរបស់ស្ទីវវ៉ូស្នៀក ហើយឈ្មោះ ថា អេបផល ចបគាត់នឹកឃើញក្រោយពីគាត់បានទៅលេងចំការអេបផល ឬចំការផ្លែប៉ម

បើមើលគិតមើលទៅ វាដូចជាមិនត្រូវគ្នាទាល់តែសោះ។ មនុស្សដែលប្រើថ្នាំមើលមមាយ ហើយចូល ចិត្តសមាធិព្រលឹងវិញ្ញាណ បែរជាមកបង្កើតកុំព្យូទ័រឯណាឯណោះទៅវិញ។ កាលណានោះ ចបគាត់ ស្រមៃចង់បង្កើតអាជីវកម្មមួយដោយខ្លួនឯង ហើយចៃដន្យ មិត្តភ័ក្តិគាត់ស្ទីវវ៉ូស្នៀក ក៏បានរកឃើញ គំនិតច្នៃប្រតិដ្ឋបង្កើតកុំព្យូទ័រឯកជន (PC personal computer) ជំនាន់ថ្មីមួយ ចំពេលនោះដែរ។ សុំបញ្ជាក់ថា ទាំងកុំព្យូទ័រឡេបថប់ ទាំងកុំព្យូទ័រតាំងលើតុសុទ្ធតែជាប្រភេទកុំព្យូទ័រឯកជន។

ចបបានជម្រុញឲ្យស្ទីវវ៉ូស្នៀកចូលរួមឡើងធ្វើបទបង្ហាញពីគំនិតខ្លួនដើម្បីប្រមូលវិនិយោគិនមកវិនិយោគ លើគម្រោងរបស់ខ្លួន នៅក្នុងក្លឹបកុំព្យូទ័រហូមប្រ៊ូ។ ក្លឹបកុំព្យូទ័រហូមប្រ៊ូនេះគឺជាកន្លែងដែលអ្នកស្រឡាញ់ងប់ងុលនឹងកុំព្យូទ័រមកជួបជុំគ្នាដើម្បីដោះដូរគំនិតគ្នា ហើយទីនោះគឺជាកន្លែងដែលឲ្យតម្លៃទៅលើ បច្ចេកវិទ្យា និងការជំនះវប្បធម៌ ឬគំនិតចាស់ៗដែលៗ ដែលត្រូវនឹងចំណង់ចំណូលចិត្តចបស្រាប់។

ស្ទីវវ៉ូស្នៀកបានយល់ឃើញថាកុំព្យូទ័រកាលសម័យនោះត្រូវការគ្រឿងបំណែកដាច់ដោយឡែកៗពីគ្នា ជាច្រើនដើម្បីដំណើរការ ដែលស្មុគស្មាញពិបាកគ្រប់គ្រង និងប្រើប្រាស់។ ក្នុងប្រជុំនោះ ស្ទីវវ៉ូស្នៀក បាន

លើកឡើងថា កុំព្យូទ័រគួរតែដំណើរការនៅក្នុងប្រអប់មា៉ស៊ីនមួយដែលមានគ្រឿងសម្រាប់ដំណើរ ការទាំងអស់នៅក្នុងនោះ ហើយគួរតែមានក្តារចុចមួយ អេក្រង់មួយ និងម៉ៅមួយ ពោលគឺមានមួយចប់ នៅលើតុតែងម្តង។

ដំបូងឡើយ ស្ទីវវ៉ូស្នៀកគិតថាចែករំលែកគំនិតនេះដោយសេរីមិនចាំបាច់ចង់បានការវិនិយោគអីទេ នៅក្នុងក្លឹបនោះ។ ប៉ុន្តែចបទទូចប្រាប់ថាពួកគាត់ទាំងពីរនាក់អាចនឹងរកបានប្រាក់ចំណេញពីគំនិតច្នៃប្រតិដ្ឋរបស់ស្ទីវវ៉ូស្នៀក។

មិនបង្អង់យូរ ស្ទីវវ៉ូស្នៀក និងចបបានបង្កើតក្រុមហ៊ុនមួយឡើង។ មុននឹងបង្កើត ពួកគាត់ត្រូវ រកឈ្មោះដាក់ឲ្យក្រុមហ៊ុនរបស់ពួកគាត់។ ក្រោយពីបានទៅលេងចំការផ្លែប៉ម (ឬអេបផល) ចបក៏បាន គិតថាអេបផលគឺជាឈ្មោះដែលទំនងបំផុត ពីព្រោះវាសាមញ្ញ កំប្លែង និងនរណាៗក៏ធ្លាប់ស្គាល់ ធ្លាប់លឺ។ ក្រោយមក ពួកគាត់ក៏សម្រេចយកឈ្មោះថា អេបផលនេះតែម្តងទៅ។ ជាមួយនឹងដើមទុន ត្រឹម ១,៣០០ដុល្លារ ពួកគាត់ក៏បានបង្កើតក្រុមហ៊ុន អេបផលកុំព្យូទ័រ (Apple Computer) ឡើងនៅក្នុងថ្ងៃទី០១ មេសា ១៩៧៦ ។

ស្ទីវវ៉ូស្នៀក និងចបបានចំណាយពេលមួយខែប្រឹងប្រែងយ៉ាងខ្លាំងទៅផលិតកុំព្យូទ័រ ១០០គ្រឿងដោយ ដៃ។ ពាក់កណ្តាលបានលក់ទៅឲ្យហាងលក់កុំព្យូទ័រ ហើយពាក់កណ្តាលទៀតគឺលោកទៅឲ្យមិត្តភ័ក្ត និងអតិថិជនរាយរងដទៃទៀត។

បន្ទាប់ពីចំណាយពេល ៣០ថ្ងៃនោះក្រោយមក ពួកគេក៏បានបង្កើតកុំព្យូទ័រប្រេនអេបផលដំបូងឡើង ឈ្មោះថា អេបផលវ៉ាន (Apple I)។ អេបផលកុំព្យូទ័រក៏ចាប់ផ្តើមទទួលបានប្រាក់ចំណេញក្រាស់ក្រែល ពីប្រេនផលិតផលដំបូងនេះរបស់ខ្លួន។ ទាំងពីរនាក់បានរួមគ្នាបង្កើតក្រុមការងារដ៏ខ្លាំងមួយក្រុម។ ស្ទីវវ៉ូស្នៀកទទួលការងារខាងវិស្វកម្មបង្កើតកុំព្យូទ័រ រីឯចបវិញគឺជាអ្នកគិតទៅលើទស្សនៈវិស័យ។ ចបគាត់មើលឃើញថាកុំព្យូទ័រឯកជនអាចនឹងផ្លាស់ប្តូរពិភពលោកបាន។

ទាញយកអេបឥឡូវនេះ

# ៤
# ភាពនិយមភាពល្អឥតខ្ចោះ ឬសុក្រិតភាពពេកបានធ្វើឲ្យចបមានចរិកលក្ខណៈ គ្រប់គ្រងត្រួតត្រាលើបុគ្គលិកជ្រុល និងក្លាយជាមនុស្សឆេវឆាវឃោរឃៅ

ពីអន្លើយើងបានដឹងពីប្រវត្តិខ្លះមកហើយពីការបង្កើតក្រុមហ៊ុនអេបផល ឥឡូវយើងមកមើល ចិរកលក្ខណៈការងាររបស់គាត់ម្តង។ ស្ទីវចបគឺមនុស្សដែលមិនទៀងទាត់ និងពិបាកនឹងទាយត្រូវ ណាស់ បើយោងតាមមនុស្សដែលស្គាល់ និងធ្វើការងារផ្ទាល់ជាមួយគាត់។ បើនរណាម្នាក់ធ្វើការងារ មិនត្រូវចិត្ត មិនត្រូវស្តង់ដារខ្ពស់គាត់ទេ គាត់នឹងបោះកំហឹងទៅដាក់ម្នាក់នោះភ្លាម ព្រមទាំងស្តីប្រមាថ ផ្ទាល់មាត់ទៅគេទៀតផង។ មូលហេតុដែលគាត់គ្រប់គ្រងបុគ្គលិកគាត់ជ្រុល និងមានកំហឹងជ្រុល គឺដោយសារតែគាត់គឺជាប្រភេទមនុស្សសុក្រឹត្យនិយមដែលមានចេះអឍ្យាស្រ័យ ឬមនុស្សចូលចិត្ត ភាពល្អឥតខ្ចោះមិនខ្លាចនឹងស្តីឲ្យគេ។ ចបគាត់ចង់ឲ្យផលិត ផលកុំព្យូទ័រប្រេន អេបផលធូ ( Apple II ) ផលិតចេញមកមានភាពល្អឥតខ្ចោះគ្រប់លក្ខណៈទាំងអស់ តាំងពីដើមរហូតដល់ចប់។ ដល់ពេលគាត់ ចង់ឲ្យល្អឥតខ្ចោះពេកទៅ ក្រុមការងារគាត់ម្នាក់ៗខ្សមខ្សោយអស់កម្លាំង និងធន្ទះធ្វើការងារជាមួយគាត់ ទោះជាប្រេនអេបផលធូបានផលិតចេញមកលក់ដាច់ជោគជ័យក្នុងឆ្នាំ ១៩៧៧ យ៉ាងណាក៏ដោយ។

ពេលកិច្ចការបុគ្គលិកណាម្នាក់មិនសូវជាល្អ ឬអន់ ចបនឹងប្រាប់ថាការងារអ្នកឯងគឺដូចអាចម៍អញ្ចឹង។ ហើយបើឃើញថាមានកំហុសមិនល្អសូម្បីតែប៉ុនក្រចកដៃ ក៏គាត់ខឹងសម្បារភ្លាមៗតែម្តង។

ពេលក្រុមហ៊ុនអេបផលកាន់តែរីកធំទៅៗ ចបកាន់តែសាហាវឃោរឃៅខ្លាំងទៅៗដែរ។ នៅទីបំផុត លោកម៉ែកស្កុត ( Mike Scott ) ត្រូវបានគេតែងតាំងធ្វើជាប្រធានក្រុមហ៊ុនអេបផល ហើយកិច្ចការសំខាន់ របស់គាត់គឺត្រូវគ្រប់គ្រងស្ទីវចបឲ្យជាប់កុំឲ្យគាត់សាហាវឃោរឃៅពេក។

លោកម៉ែកស្កុតជាទូទៅត្រូវប្រឈមមុខនឹងចបជារឿយៗទាក់ទងបញ្ហាពិបាកៗដែលបុគ្គលិក រាយការណ៍ថាពួកគេមិនចេះធ្វើការ និងគ្មានកម្លាំងធ្វើការឲ្យចបឡើយ។ ជាទូទៅ វាធ្វើឲ្យពួកគេមិន សូវជាត្រូវរ៉ូវនឹងគ្នាប៉ុន្មានទេ។ ជួនកាល ស្ទីវចបខឹងពេករហូតដល់ថ្នាក់ស្រក់ទឹកភ្នែកពីព្រោះខ្លួនហាក់ ដូចជាមិនអាចបញ្ឈ ឬគ្រប់គ្រងនរណាម្នាក់បានហើយគ្រប់គ្រងអេបផលកាន់តែលំបាកទៅៗ។
គាត់កាន់តែខឹងសម្បារីតតែខ្លាំង ពេលលោកម៉ែកស្កុតបានព្យាយាមដាក់កំហិតភាពនិយមសុក្រឹត្យភាព របស់គាត់ ពោលគឺដាក់កំហិតកំុឲ្យគាត់គិតពីភាពល្អឥតខ្ចោះពេក។ ប៉ុន្តែសម្រាប់លោកម៉ែកស្កុតវិញលោកគ្រាន់តែចង់ឲ្យចបយកភាពល្អឥតខ្ចោះនិយមរបស់គាត់លុបលើបហេតុផលខ្លាំងពេក ឲ្យយល់ពី អារម្មណ៍ និងហេតុផលក្រុមការងារគាត់ផង។

មានពេលមួយនោះ លោកមែ៉កស្កុតបានចូលធ្វើអន្តរាគមន៍ដោយសារតែចបគិតថាពណ៌ត្នោតខ្ចី ប្រមាណ ២,០០០ពណ៌គ្មានមួយណាត្រូវនឹងពណ៌កេសមា៉ស៊ីនប្រេនអេបផលធូឡើយ ហើយមួយទៀត ចបគាត់ចង់ចំណាយពេលច្រើនថ្ងៃទៀតដើម្បីសម្រេចចិត្តមើលថាតើគែមជ្រុងកេសម៉ាស៊ីនអេបផលធូ ហ្នឹងគួរតែមូល ឬទាលប៉ុណ្ណា

ទើបល្អ។ ប៉ុន្តែលោកមែ៉កស្កុតផ្តោតសំខាន់ធ្វើម៉េចឲ្យប្រអប់កេសមា៉ស៊ីន នោះផលិតចេញ និងចេញលក់ឆាប់ៗទៅ មិនត្រូវស៊ាំញ៉ាំច្រើនទេ។ ដោយសារតែប្រេនអេបផលធូ ដែលអនុម័តឲ្យផលិតចេញនោះបានលក់ដាច់ទទួលបានជោគជ័យខ្លាំងនៅលើទីផ្សារ ស្ទីវចបក៏មិនសូវជាមានទឹកមាត់ទៅខឹងសម្បារខ្លាំងនឹងលោកម៉ែកស្កុតដែរ។

## ៥

## ចរិតលក្ខណៈចូលចិត្តភាពសុក្រិត្យនិយម និងនិយមភាពល្អឥតខ្ចោះ បានធ្វើឲ្យគាត់ផលិតកុំព្យូទ័រប្រេនម៉ាក់ស៊ីនថ្មីសបានលក់យ៉ាងជោគជ័យ តែក៏បានធ្វើឲ្យត្រូវគេបណ្តេញចេញពីក្រុមហ៊ុនខ្លួនឯងដែរ

ប្រេនអេបផលធូត្រូវបានលក់ដាច់អស់ប្រមាណ ៦លានគ្រឿង ប៉ុន្តែសម្រាប់ចប ជោគជ័យនេះមិនទាន់ ចាត់ទុកថាជាជោគជ័យនៅឡើយទេ ពីព្រោះគំនិតច្នៃប្រតិដ្ឋប្រេនអេបផលធូនេះមិនមែនជារបស់លោកទេ តែជារបស់ស្ទីវវ៉ូស្នៀក។ ដូច្នេះ គាត់ចង់បង្កើតមួយជារបស់ផ្ទាល់ខ្លួន និងល្អជាងប្រេនអេបផលធូ។ គាត់ចង់បង្កើតម៉ាស៊ីនកុំព្យូទ័រមួយដែលគាត់ប្រើពាក្យថា “ម៉ាស៊ីនដែលជាន់ផ្អៀងពិភពលោក”។ ក្រោយមក

គាត់ក៏ឈប់បង្កើតបន្តប្រេនអេបផលធូហើយ តែគាត់បង្កើតប្រេនថ្មីមួយទៀតឈ្មោះថា ម៉ាកស៊ីនថូស ( Macintosh ) ។ ម៉ាកស៊ីនថូសរឹតតែធ្វើឲ្យកុំព្យូទ័រឯកជនប្រែប្រួលមុខមាត់កាន់តែ ខ្លាំងឡើងៗ ហើយចបត្រូវបានមនុស្សម្នាចាត់ទុកថាជានិមិត្តរូបនៃបច្ចេកវិទ្យា ។

ប៉ុន្តែម៉ាកស៊ីនថូសនេះមិនមែនជាគំនិតច្នៃប្រតិដ្ឋចបទាំងស្រុងទេ តែជាគាត់បានលួចយកគម្រោង ម៉ាកស៊ីនថូសនេះពីអ្នកបង្កើតវាគឺលោក ចេហ្វរ៉ាស់ឃីន ( Jef Raskin ) ដែលជាអ្នកជំនាញខាងផ្នែង អេក្រង់កុំព្យូទ័រ ។ ចបបានយកគំនិតនោះ និងបង្កើតជាម៉ាស៊ីនមួយដែលដើរនៅលើមីក្រូប្រូសេសសឺ ដែលមានកម្លាំងពេញល្មមនឹងអាចដាក់ក្រាហ្វិកសំខាន់ៗទំនើបៗបាន ហើយនិងអាចបញ្ជាស្ទើរតែតែ ស្រុងបានដោយម៉ៅចុច ។

កុំព្យូទ័រឯកជនប្រេនម៉ាក់ស៊ីនថូសទទួលបានជោគជ័យដែលគ្មានអ្វីមកអាចប្រៀបផ្ទឹមស្មើបានឡើយ ។ មូលហេតុមួយផ្នែកគឺដោយសារតែការធ្វើយុទ្ធនាការទីផ្សារមិនសំចៃ រួមទាំងការផ្សាយពាណិជ្ជកម្ម តាមទូរទស្សន៍ដែលអន្ទងអារម្មណ៍ទស្សនិកជនផងដែរ ។ ដោយសារតែប្រជាប្រិយការផ្សាយ ពាណិជ្ជកម្ម ការដាក់លក់ប្រេនម៉ាកស៊ីនថូសបណ្តាលឲ្យមានការល្បីតៗគ្នាទាំងស្ទីវចបផង ទាំងម៉ាក់ស៊ីនថូសផង ។

ចបជាមនុស្សដែលឆ្លាតពីដើមរហូតដល់ចប់ ។ គាត់បានអនុញ្ញាតឲ្យមានការរៀបចំកម្មវិធីសំភាសន៍គាត់ ទ្រង់ទ្រាយធំៗជាមួយនឹងទស្សនាវដ្ដីល្បីៗជាច្រើន ។ គោលបំណងគាត់គឺដើម្បីអូសទាញបញ្ចុះបញ្ចូល ឲ្យ

អ្នកកាសែតគិតថាការសំភាសន៍របស់គាត់មានលក្ខណៈពិសេសដាច់ពីគេ។

យុទ្ធសាស្ត្រគាត់ពិតបានផល ហើយប្រេនម៉ាក់ស៊ីនថូសបានធ្វើឲ្យចបល្បីល្បាញ និងមានទ្រព្យស្តុក ស្តម្ភ។ កាលនោះគាត់ហាក់ដូចជាតារាម្នាក់អញ្ចឹង។ ប៉ុន្តែ ចរិតនិស្ស័យដែលធ្វើឲ្យគាត់ផលិត ម៉ាកស៊ីនថូសលក់បានជោគជ័យក៏ជាចរិតលក្ខណៈដែលធ្វើឲ្យគេបណ្តេញគាត់ចេញពីក្រុមហ៊ុនគាត់ ឆាប់ៗខាងមុខនេះដែរ។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអេបផលបានសម្រេចចិត្តបណ្តេញចបចេញពីក្រុមហ៊ុននៅក្នុងឆ្នាំ ១៩៨៥។ មូលហេតុគឺដោយសារតែចរិតសុក្រិត្យនិយម ឬចរិតនិយមភាពល្អឥតខ្ចោះ និងឥរិយាបថ គាបសង្កត់បុគ្គលិកមិនដែលថមថយចុះម្តងណាឡើយ។ បើសិននរណាម្នាក់ធ្វើមិនត្រូវ មិនតាមស្តង់ ដារគាត់ ឬធ្វើមិនបានល្អឥតខ្ចោះ គាត់នឹងជេរបុគ្គលិកថា “អាមនុស្សឆ្កួត” ភ្លាមៗតែម្តង។ ចរិតបាបសារ នេះហើយដែលបានធ្វើឲ្យគាត់ដើរដល់ផ្លូវទាល់ជាមួយក្រុមហ៊ុន។

# ៦

# ក្រោយពីចេញពីអេបផល ចបមកបង្កើតក្រុមហ៊ុននិក និងទិញក្រុមហ៊ុនពិសារ។ តែសុទ្ធតែបរាជ័យលើរឿងបង្កើតកម្មវិធីកំព្យូទ័រ និងគ្រឿងកំព្យូទ័រ តែត្រូវបាន់នឹង ភាពយន្តតុក្កតាទៅវិញ

គាត់បានមកបង្កើតក្រុមហ៊ុនថ្មីមួយទៀតដែលមានឈ្មោះថានិកកុំព្យូទ័រ (NeXT) បន្ទាប់ពីបានត្រូវ បានដេញចេញ និងរសាយចិត្តក្រុមហ៊ុនអេបផល។ គាត់យល់ថា អញ្ចឹងក៏ស្រួលដែរ ពីព្រោះគាត់អាច ធ្វើអ្វីៗទៅតាមចិត្តគាត់មិនថាអាក្រក់ ឬល្អយ៉ាងណាក៏ដោយ។ ក្រុមហ៊ុននិកកុំព្យូទ័រនេះផ្តោតទៅលើ ទីផ្សារអប់រំដោយបង្កើតកុំព្យូទ័រប្រេនថ្មីឈ្មោះថានិក ដូចឈ្មោះក្រុមហ៊ុនដែរ។ ក្នុងគម្រោងថ្មី ចបរីករាយខ្លាំងណាស់ដែលបានធ្វើតាមអ្វីដែលគាត់ងប់ស្រឡាញ់ ពោលគឺការងារ ឌីស្សាញរចនា។ គាត់បានចំណាយលុយរហូតដល់ទៅ ១០០,០០០ដុល្លារដើម្បីឲ្យគេគូសឌីស្សាញ ឡូហ្គូរបស់គាត់ទៅតាមអ្វីដែលគាត់បានគូសគ្រោងឌីស្សាញឲ្យ។ ចបចង់ឲ្យប្រអប់កេសម៉ាស៊ីនកុំព្យូទ័រ របស់និកជាប្រអប់គូបផតខ្មៅមួយ។ គ្រាន់តែថ្លៃពុម្ពសម្រាប់ផលិតប្រអប់កេសម៉ាស៊ីនកុំព្យូទ័រ ចំណាយអស់រហូតដល់ទៅ ៦៥០,០០០ ដុល្លារបាត់ទៅហើយ។ គាត់តែថាធ្វើហើយ គឺដឹងតែធ្វើហើយ។ គាត់មិនស្តាប់នរណាម្នាក់ទេ។ បែបនេះហើយដែលធ្វើឲ្យគម្រោងផលិតកុំព្យូទ័រនិកនោះស្ទើរតែអស់ខ្ទង់ចំណាយ។ គម្រោងកុំព្យូទ័រនិកនេះត្រូវបានពន្យារពេលរាប់ឆ្នាំ។ ចុងក្រោយពេលកុំព្យូទ័រនិកបាន ផលិតចេញហើយ វាក៏លក់មិនដាច់ទៀតដោយសារតែមានតម្លៃថ្លៃខ្លាំងពេកសម្រាប់អតិថិជនអ្នកប្រើ ប្រាស់។ កុំព្យូទ័រនិក និងចបមិនអាចធ្វើព្យុះធ្វើភ្លៀងខ្លាំងនៅក្នុងទីផ្សារបានដូចមុនទេ ពីព្រោះតម្លៃវាក៏ ថ្លៃ ហើយកុំព្យូទ័រនោះក៏មិនសូវមានកម្មវិធីច្រើនប៉ុន្មានដែរ។

ប៉ុន្តែចបក៏បានឆ្លៀតឱកាសទិញភាគហ៊ុនរបស់ក្រុមហ៊ុនមួយដែលមានឈ្មោះថាពិចសារ (Pixar) ក្នុងកំឡុងពេលនោះដែរ។ គាត់ទិញភាគហ៊ុនភាគច្រើនរបស់ក្រុមហ៊ុនពិចសារ ពីព្រោះគាត់ចង់បាន តំណែងជាប្រធានក្រុមប្រឹក្សាភិបាល។

ប៉ុន្តែចបបានលង់ខ្លួនយ៉ាងជ្រៅ ខាតទាំងលុយក្នុងក្រុមហ៊ុននិកកុំព្យូទ័រ ជាប់ផុងទាំងលុយជិត ៥០លានដុល្លារនៅក្នុងក្រុមហ៊ុនពិចសារដែរ នៅមុនឆ្នាំ ១៩៨៨។ ប៉ុន្តែដល់ឆ្នាំ ១៩៨៨ វីដេអូជីវចល ខ្លីមួយឈ្មោះថា តុក្កតាកំប៉ុង (Tin Toy) របស់ក្រុមហ៊ុនពិចសារបានទទួលពានរង្វាន់ "ភាពយន្តជីវ ចលខ្លីល្អបំផុតប្រចាំឆ្នាំ ១៩៨៨" ។ ដោយបានលង់ខ្លួនខាតអស់ប៉ុន្មានឆ្នាំមុនផង ចបក៏បានបង្វែរពី ការផ្តោតពីការផលិតកម្មវិធីកុំព្យូទ័រ និងគ្រឿងកំុព្យូទ័រទៅផលិតខ្សែភាពយន្តគំនូរជីវចលដែលអាចនឹង រកបានចំណូលក្រាស់ក្រែលវិញ។

មែន! បន្ទាប់បានបង្វែរមកផ្តោតលើទីផ្សារភាពយន្តជីវចល ក្រុមហ៊ុនពិចសារក៏ទទួលបានជោគជ័យ មហាសម្បើម។ ពេលក្រុមហ៊ុននេះបានលក់ភាគហ៊ុនជាសាធារណៈ ភាគហ៊ុនរបស់ចប ពោលគឺ ៨០% បានកើនឡើងរហូតដល់ទៅ ១.២ពាន់លានដុល្លារ។ វាស្មើនឹងលុយគាត់វិនិយោគដំបូងគុណនឹង ២០ដង។ ប៉ុន្តែក្រុមហ៊ុនពិចសារមិនបានធ្វើតែម្នាក់ឯងទេ តែបានចាប់ដៃគូជាមួយនឹងក្រុមហ៊ុន ដេសនី (Disney) ហើយបង្កើតវីដេអូជីវចលមួយដែលមានចំណងជើងថា ដំណើរជីវិត

របស់កុត្តកា (Toy Story)។ រឿងតុក្កតានេះត្រូវបានចាក់បញ្ចាំងដំបូងនៅក្នុងឆ្នាំ ១៩៩៦ ហើយរកបានចំណូលកំពូលគេប្រចាំឆ្នាំ នោះដែរ។

# ៧

# ចបបានវិលមករកគ្រួសារបង្កើតគាត់វិញ និងបង្កើតគ្រួសារផ្ទាល់ខ្លួនមួយ និងផ្សះផ្សារជាមួយ កូនស្រីដែលគាត់បានបោះបង់ចោលពីមុន

បន្ទាប់ពីចាកចេញពីក្រុមហ៊ុនអេបផល ក្នុងរយៈពេល១២ឆ្នាំនោះ ស្ទីវចបបានប្រឹងប្រែងរៀនជំនាញ បច្ចេកទេសអាជីពៗជាច្រើន។ ទន្ទឹមនឹងនោះគាត់ក៏ព្យាយាមស្វែងយល់ពីប្រវត្តិគាត់ផ្ទាល់ខ្លួនដែរ ក្រោយពីម្ដាយចិញ្ចឹមគាត់បានចែកឋានទៅនៅឆ្នាំ ១៩៨៦។ ទីបំផុត គាត់ក៏បានជួបម្ដាយបង្កើតគាត់ មែន គឺលោកស្រី ចូនសាយបល។ លោកស្រីចូនចូនសាយបលពិតជាក្ដុកក្ដួលមែនទែន និងសូមឲ្យ ចបអភ័យទោសឲ្យគាត់ដែលបំបោះបំបង់គាត់ទុកឲ្យអ្នកដទៃចិញ្ចឹមគាត់។

គាត់ក៏មានការភ្ញាក់ផ្អើលដែរដែលគាត់មានប្អូនស្រីបង្កើតម្នាក់ទៀត ឈ្មោះ ម៉ូណា ស៊ីមសាន់ (Mona Simpson។ ពួកគាត់ទាំងពីរនាក់បងប្អូនចុងក្រោយមកមានភាពស្និទ្ធស្នាលនឹងគ្នា ពីព្រោះពួកគេ សុទ្ធតែស្រឡាញ់ចូលចិត្តសិល្បៈ និងមានឆន្ទៈខ្ពស់ដូចគ្នា។

ប៉ុន្តែស្ទីវចបអន់ចិត្តនឹងប្អូនស្រីគាត់ម៉ូណាស៊ីមសាន់បន្តិចត្រង់ថាប្អូនស្រីគាត់បានតែង និងបោះពុម្ពរឿង ប្រឡោមលោកមួយដែលមានចំណងជើងថា បុរសធម្មតាម្នាក់ (A Regular Guy)។ មូលហេតុគឺដោយ សារតែរឿងប្រឡោមលោកដែលចេញផ្សាយនៅឆ្នាំ ១៩៩៦នោះ គឺមានតួឯកគឺជាស្ទីវចប ប៉ុន្តែបាន បង្ហាញចរិតនិស្ស័យមិនល្អជាច្រើនរបស់ស្ទីវចបនៅក្នុងរឿងប្រឡោមលោកនោះ។ ចបសម្រេចចិត្ត មិន

អានរឿងនោះទេ ពីព្រោះគាត់មិនចង់ឲ្យខ្លួនឯងមានអារម្មណ៍ខឹងទៅលើប្អូនស្រីដែលខ្លួនទើបរក ឃើញឡើយ។

នៅឆ្នាំ ១៩៩១ ចបក៏បានជួប និងរៀបការជាមួយអ្នកនាង ឡូរេន ផូវែល (Laurene Powell)។ អ្នកទាំងពីរបង្កើតបានកូនដំបូងគាត់ឈ្មោះថា រីតផូលចប (Reed Paul Jobs) បន្ទាប់មកអេរីន (Erin) និងអុីវ (Eve)។ ប៉ុន្តែចបក៏ធ្លាប់មានកូនស្រីម្នាក់ជាមួយសង្សារចាស់គាត់ទៅហើយតាំងពីមុន ក្រុមហ៊ុនអេបផលក្លាយទៅជាក្រុមហ៊ុនល្បីមកម្ល៉េះ។ កូនស្រីម្នាក់នោះមានឈ្មោះថា លីសា ប្រេនណាន់ (Lisa Brennan) ដែលស្ទីវចបបានបំបោះបំបង់ចោល ពីព្រោះគាត់ខ្លាចខូចការងាររបស់គាត់។ តែដោយសារមានការលើកទឹកចិត្តពីប្រពន្ធគាត់អ្នកស្រីផូវែលហើយខ្លួនលោកក៏ចង់ចំណាយពេលរស់ នៅជាមួយលីសាដែរ គាត់និងផូវែលមានទទួលយកលីសាមករស់នៅជាមួយពួកគាត់ រហូតដល់នាងបានចូលរៀនសាកលវិទ្យាល័យហាវីត។ ចបបានខំប្រឹងប្រែងព្យាយាមធ្វើជាឪពុកដែលសកម្ម ចំពោះលីសាដោយសារតែខ្លួនធ្លាប់បោះបង់កូននេះចោល។ ប៉ុន្តែលីសាជាស្លឹកឈើដែលជ្រុះមិនឆ្ងាយ ពីគល់ទេ គឺគាត់មានចរិកឆាប់ខឹងឆេវឆាវដូចជាចបដែរ។ ពេលខ្លះពេលខឹងគ្នាម្តងៗពួកគាត់មិន និយាយរកគ្នារហូតដល់រាប់ខែឯណោះ។ ចរិតរបស់ចបគឺមានតែពីរទេ បើមិនចូលចិត្តងប់ងល់ខ្លាំងទេ គឺជឹងតែស្អប់ខ្លាំងហើយ។ និយាយរួមទៅ ការរស់នៅប្រាស្រ័យទាក់ទងមនុស្សក្នុងគ្រួសារគាត់ គឺមិនខុសគ្នាអីពីការណ៍ដែលគាត់ប្រាស្រ័យទាក់ទងនឹងបុគ្គលិកគាត់ទេ។

ទាញយកអេបឥឡូវនេះ

# ៨
## ការធ្លាក់ខ្លួនរបស់អេបផលបង្ខំឲ្យស្ទីវចបត្រឡប់មកជួយអេបផលវិញ។ តែចបបាន ប្រមូលអំណាចខ្លួនយកមកវិញ និងបណ្តេញចោលក្រុមប្រឹក្សាភិបាលចាស់ៗ ដើម្បីគាត់បានធ្វើការងារដោយស្រួល

ឥឡូវយើងមកមើលក្រុមហ៊ុនអេបផលវិញម្តង ក្រោយពេលស្ទីវចបចាកចេញពីក្រុមហ៊ុននេះ។ ប៉ុន្មានឆ្នាំ ក្រោយពេលចបចាកចេញពីអេបផល អេបផលបានបរាជ័យជាមួយនឹងរឿងជាច្រើន។ នៅឆ្នាំ ១៩៩៦ ក្រុមហ៊ុនក៏បានតែងតាំងលោកហ្គីលអាមីលីអូ (Gil Amelio) ជាស៊ីអុីអូ ដើម្បីដោះស្រាយបញ្ហានេះ។ លោកហ្គីលអាមីលីអូចង់បានស្ទីវចបមកជួយក្រុមហ៊ុនអេបផលវិញដើម្បីបង្កើតក្រុមការងារដែលមាន គំនិតថ្មីស្រឡាងមួយ។ ដើម្បីឲ្យស្ទីវចបចូលមកជួយធ្វើជាទីប្រឹក្សាឲ្យអេបផលបាន លោកក៏បាន សម្រេចចិត្តទិញក្រុមហ៊ុន និក និងកម្មវិធីរបស់និក។

ឪកាសស្ទីវចបក៏បានមកដល់វិញ គាត់បានព្យាយាមចាប់យកកិច្ចការជាច្រើនយកមកគ្រប់គ្រងក្នុងដៃ វិញ។ ហើយគាត់ដាក់បុគ្គលិកសំខាន់គាត់នៅនិកឲ្យនៅតាមតំណែងខ្ពស់ៗក្នុងក្រុមហ៊ុនអេបផល ដើម្បីបង្កើតគ្រឹះអំណាចរបស់គាត់។ ស្របពេលនោះដែរ ក្រុមប្រឹក្សាភិបាលចង់តែងតាំងស្ទីវចប ជាស៊ីអុីអូសារជាថ្មី ពីព្រោះពួកគេគិតថាលោកហ្គីលអាមីលីអូមិនមែនជាអ្នកអាចជួយសង្គ្រោះអេបផល បានទេ។ ប៉ុន្តែចបបដិសេដមិនទទួលយកទេ ហើយសុំត្រឹមនៅតំណែងជាទីប្រឹក្សាដដែល ហើយក៏ជួយ រកស៊ីអុីអូថ្មីឲ្យដែរ។ ចបបានប្រើមុខងារទីប្រឹក្សារបស់គាត់ដើម្បីកសាងឥទ្ធិពលខ្លួនឡើងវិញនៅក្នុង ក្រុមហ៊ុនអេបផល។ គាត់ថែមទាំងបង្ខំឲ្យក្រុមប្រឹក្សាភិបាលដែលធ្លាប់ចង់តែងតាំងគាត់ឲ្យឡើងកាន់ តំណែងស៊ីអុីអូនោះលាឈប់ពីតំណែងវិញម្តង

ដោយសារតែគាត់មានអារម្មណ៍ថាវត្តមានពួកគេធ្វើឲ្យ គាត់ជួយស្រោចស្រង់ក្រុមហ៊ុនយឺតយ៉ាវ។

ក្នុងអំឡុងពេលនោះដែរ គាត់ក៏បានបង្កើតការសហការគ្នាជាដៃគូជាមួយគូសត្រូវអេបផល គឺម៉ៃក្រូសូហ្វ ( Microsoft )។ ពួកគេសហការគ្នាដើម្បីបង្កើតកម្មវិធីមីក្រូសូហ្វអ័រហ្វីសស៊េរីថ្មីមួយសម្រាប់កុំព្យូទ័រម៉ាក។ ការសហការគ្នាលើគម្រោងនេះចុងក្រោយបានធ្វើឲ្យមានជម្លោះគ្នានឹងគ្នារាប់ឆ្នាំទាក់ទងរឿងកម្មសិទ្ធិ ឡើងតុលាការជាច្រើនលើកច្រើនសារ។ ប៉ុន្តែគម្រោងថ្មីនេះក៏បានធ្វើឲ្យភាគហ៊ុនអេបផលឡើងដូចកាំជ្រួចដែរ។

ទីបំផុត គាត់ក៏បានទទួលតំណែងជាស៊ីអុីអូរបស់អេបផល ហើយគាត់បានសម្រេចចិត្តកាត់ចោលផលិត ផលមួយចំនួន ដើម្បីឲ្យមានអេបផលផ្តោតទៅលើតែផលិតផលពីរបីមុខទៅបានហើយ គឺមកផ្តោតតែលើកុំព្យូទ័រតាំងលើតុ និងឡេបថប់ ទាំងសម្រាប់អ្នកប្រើប្រាស់ធម្មតាទាំងសម្រាប់អ្នកប្រើប្រាស់ក្នុង ក្រុមហ៊ុន។ តែ៤មុខនេះទេ។

ចបពិតជាអាចជួយស្រោចស្រង់អេបផលឲ្យរួចផុតពីចង្កូមមច្ចុរាជពិតប្រាកដមែន ពីព្រោះក្នុងពេលដែល គាត់ឡើងកាន់តំណែងសុីអុីអូពេញមួយឆ្នាំក្នុងឆ្នាំ១៩៩៨ អេបផលក៏បានស្គាល់លុយចំណេញជាថ្មីម្តង ទៀតចំនួន ៣០៩លានដុល្លារអាមេរិក។ បើមើលទៅឆ្នាំទៅមិ

ញវិញ អេបផលខាតរហូតដល់ជាង ១ពាន់លានដុល្លារអាមេរិកឯណោះ។

# ៩
# ចបបង្កើតបានអាយម៉ាក់ (iMac) ក្រោយពីបានជួបដៃគូអ្នកឌីស្សាញពោរពេញ ទេពកោសល្យ និងការស្រមើស្រមៃម្នាក់

អេបផលបានស្គាល់ដំណាក់កាលរីកចម្រើនបំផុតមួយរបស់ខ្លួន នៅពេលស្ទីវចបបានរកឃើញលោក ចននី អុីវ ដែលជាអ្នកឌីស្សាញដ៏មានទេពកោសល្យម្នាក់។ ស្ទីវចបបានផ្តល់ឥទ្ធិពលឲ្យចននីអុីវជាបុរសខ្លាំងទី២បន្ទាប់ពីលោក។ មូលហេតុដោយសារចននីអុីវជាអ្នកឌីស្សាញដែលមានទេពកោសល្យ និងពោរពេញទៅដោយការស្រមើស្រមៃ។

ដំបូង ពួកគាត់ទាំងពីរនាក់បានបង្កើតអាយម៉ាក់ (iMac) ដែលជាកុំព្យូទ័រលើតុដែលមានតម្លៃជុំវិញ ១,២០០ដុល្លារ សម្រាប់អតិថិជនអ្នកប្រើប្រាស់ការងារសាមញ្ញៗ។

អាយម៉ាក់ក្លាយទៅជាកុំព្យូទ័រលើតុដែលលក់ដាច់លឿនបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់អេបផល នៅពេលវាដាក់ដំណើរការឲ្យលក់នៅឆ្នាំ១៩៩៨ ខែ០៥។ ក្រោយមកទៀត ចបក៏សម្រេចចិត្តបង្កើត អេបផលស្តូរ (Apple Store) ឡើងដើម្បីឲ្យក្រុមហ៊ុនអេបផលអាចគ្រប់គ្រងលើផលិតផលកម្មវិធីកំព្យូទ័រ ខ្លួនបាន។ គាត់គិតថាបើដាក់ផលិតផលកម្មវិធីកំព្យូទ័រពិសេសល្អៗរបស់ក្រុមហ៊ុនអេបផល ទៅដាក់ក្នុងផ្សារសាមញ្ញៗលក់ចម្រុះមុខ អតិថិជននឹងវង្វេងមិនដឹងរកផលិតផលកម្មវិធីកំព្យូទ័រ ពិសេសៗរបស់ខ្លួននៅទីណាមិនឃើញជាមិនខាន។

គំនិតចង់បង្កើតអេបផលស្តរ ពោលគឺផ្សារអនឡាញសម្រាប់ដាក់លក់ផលិតផលកម្មវិធីកំព្យូទ័រ មិនមាន ការឯកភាពពីក្រុមប្រឹក្សាភិបាលអេបផលឡើយ ពីព្រោះពួកគេសង្កេតឃើញថាក្រុមហ៊ុនធំៗ ជាច្រើនដែលធ្លាប់បានបង្កើតផ្សារប្រភេទនេះបានបរាជ័យច្រើនណាស់។ ប៉ុន្តែ ចបក៏នៅតែមានឱកាស បង្កើតវាដោយសាកល្បងបាន ដោយសារពាក្យបញ្ចុះបញ្ចូលដ៏ប៉ិនប្រសប់របស់លោក។

ទីបំផុត អេបផលស្តរក៏បានដាក់ឲ្យដំណើរការឡើងនៅខែ ០៥ ឆ្នាំ ២០០១ ហើយពិតជាទទួលបានជោគ ជ័យខ្លាំងបំផុតដូចអ្វីដែលចបធ្លាប់រំពឹងទុក។

# ១០
# អេបផលបានបង្កើតអាយផត អាយហ្វូន និងអាយផេតឡើងដើម្បីចង់គ្រប់គ្រង ឧបករណ៍ឌីជីថលទាំងឡាយ

ចបមានចក្ខុវិស័យចង់ឲ្យកុំព្យូទ័រឯកជនមិនមែននៅត្រឹមតែជារូបរាងកំព្យូទ័រលើតុ និងកំព្យូទ័រឡេបថប់ ប៉ុណ្ណឹងទេ តែឲ្យក្លាយទៅជាឧបករណ៍ឌីជីថលដទៃទៀតដែលយកលំនាំតាមកំព្យូទ័រឯកជន ជាពិសេសគឺឧបករណ៍ទាំងនោះត្រូវមានកម្មវិធីអស្ចារ្យៗដូចក្នុងកំព្យូទ័រឯកជនដែរ។ ដើម្បីសម្រេច យុទ្ធសាស្ត្រនេះបាន ជាដំបូង គាត់បានបង្កើតអាយផត (iPod) ដែលជាឧបករណ៍ដែលអាចផ្ទុកចម្រៀង បានរាប់ពាន់បទ ដែលមានប៊ូតុងទ្រង់ទ្រាយជារង្វង់សម្រាប់បញ្ជា និងមានអេក្រង់សម្រាប់មើល និងប្រើបច្ចេកវិទ្យាហាតឌីសថ្មី។

មនុស្សជាច្រើនមិនជឿទាល់តែសោះថាឧបករណ៍ចាក់ចម្រៀងអាយផតនេះនឹងអាចមានគេទិញក្នុងតម្លៃ ៣៩៩ដុល្លារដែលជាតម្លៃកប់ពពកមួយទេ។ ប៉ុន្តែ អាយផតពិតជាធ្វើឲ្យមនុស្សគ្រប់គ្នាស្រឡាំងកាំងពីព្រោះវាពិតជាជោគជ័យខ្លាំងមែនទែនដល់ថ្នាក់គ្រាន់តែចំណូលលក់បានពីអាយផតសរុប គឺវាស្មើនឹងពាក់កណ្ដាលរបស់ក្រុមហ៊ុនអេបផលទាំងមូលទៅហើយ។

ក្រោយមកទៀតនៅឆ្នាំ ២០០៧ ចបក៏បានបង្កើតអាយហ្វូនឡើង (iPhone)។ មូលហេតុគឺគាត់គិតថា បើគេបង្កើតទូរស័ព្ទឡើងដោយបញ្ចូលម៉ាស៊ីនចាក់ចម្រៀងក្នុងនោះស្រាប់ អាយផតគាត់នឹងដួលរលំ។ ដូច្នេះគាត់ក៏បង្កើតអាយហ្វូនដែលមានម៉ាស៊ីនចាក់ចម្រៀងក្នុងនោះឲ្យ

បានមុនគេទៅ។ ក្រោយមកទៀត ក៏នៅតែមានគេរិះគន់ដដែលថា វាមិនដែលមានអ្នកទិញទូរស័ព្ទមួយដែលមានតម្លៃ ៥០០ដុល្លារទេ។ ប៉ុន្តែយុទ្ធសាស្ត្រកំណត់តម្លៃរបស់អេបផលទៅលើអាយហ្វូនពិតជាធ្វើឲ្យម្នាក់ៗនិយាយលេងចេញ។ អាយហ្វូនពិតជាទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំង ហើយមកទល់ឆ្នាំ ២០១០ ចំណូលលក់បានមកពីអាយហ្វូនមានទំហំច្រើនជាងពាក់កណ្តាលនៃទំហំចំណូលលក់ទូរស័ព្ទដៃក្នុងលោកសរុបទៅទៀត។

យុទ្ធសាស្ត្រចុងក្រោយរបស់ចបគឺបង្កើតកំព្យូទ័របន្ទះមួយទៀត ដែលអេបផលឲ្យឈ្មោះថា អាយផេត (iPad) និងបានដាក់លក់ជាផ្លូវការនៅខែមករា ២០១០។ អាយផេតក៏ទទួលបានជោគជ័យមិន ធម្មតាដែរ។ ត្រឹមតែមួយខែដំបូងសោះ វាអាចលក់បានរហូតដល់ទៅជាង១លានគ្រឿងឯណោះ។ ហើយត្រឹមរយៈពេល ៩ខែ វាអាចលក់បានរហូតទៅដល់ ១៥លានគ្រឿង។ ប៉ុន្តែមុននឹងអាយផេតចេញ លក់ ចបបានបង្ហាញពីអាយផេតជាសាធារណៈទៅហើយ ដែលជាហេតុធ្វើឲ្យសារព័ត៌មានយកព័ត៌មាន នេះទៅធ្វើឲ្យខូចអស់រលីង។ ប៉ុន្តែត្រឹមប៉ុណ្ណឹង វាមិនបានបញ្ឈប់ភាពជោគជ័យរបស់អាយផេតឡើយ។ ពោលគឺលក់អស់ ១៥លានគ្រឿងក្នុងរយៈពេលត្រឹមតែ ៩ខែប៉ុណ្ណោះ។

# ១១
# ចរិតត្រួតត្រាគ្រប់គ្រងជារបស់ខ្លួនឯងធ្វើឲ្យចបបង្កើតការប្ដឹងប្ដល់អ្នកជុំវិញ ដែលអាចផលិតបានស្រដៀងខ្លួន

ប៊ីលហ្គេតយល់ឃើញចំពោះអាជីវកម្ម និងបច្ចេកវិទ្យាខុសស្រឡះតែម្ដង។ ប៊ីលហ្គេតមានការបើក ទូលាយច្រើន។ គាត់ព្រមលក់អាជ្ញាប័ណ្ណប្រព័ន្ធដំណើរការកំព្យូទ័រ និងកម្មវិធីនានារបស់គាត់ទាំងអស់ ទៅឲ្យភាគីទី៣។ ជាការពិត ប៊ីលហ្គេតក៏ធ្លាប់សរសេរកម្មវិធីសម្រាប់ម៉ាក់ស៊ីនថូសរបស់អេបផល ម្ដងដែរ។ ប៉ុន្តែទំនាក់ទំនងនេះបានបង្កើតឲ្យមានជម្លោះរវាងប៊ីលហ្គេត និងចបពេញមួយជីវិត។ ចបបានចោទប្រកាន់ប៊ីលហ្គេតថាប៊ីលហ្គេតបានបង្កើតប្រព័ន្ធដំណើរការវីនដូ (Windows OS) ឡើង ដោយលួចចម្លងប្រព័ន្ធដំណើរការរបស់ម៉ាក់ស៊ីនថូសរបស់ខ្លួន។ ការពិតគឺថា ទាំងម៉ាកស៊ីនថូស ទាំងវីនដូសុទ្ធតែលួចចម្លងខ្លះៗពីក្រុមហ៊ុនបច្ចេកវិទ្យាមួយទៀតឈ្មោះថា ស៊ីរ៉ក់ (Xeror)។

ក្រោយមកទៀត ចបក៏មានជម្លោះជាមួយនឹងហ្គូហ្គលដែរ។ ពេលហ្គូហ្គលបង្កើតប្រព័ន្ធដំណើរការ ទូរស័ព្ទដៃវៃឆ្លាតដែលមានឈ្មោះថា អេនត្រយ (Android OS) ចបបានចោទថាហ្គូហ្គលបានលួចយក មុខងារជាច្រើនរបស់ប្រព័ន្ធដំណើរការរបស់អាយហ្វូន។

ទាំងម៉ៃក្រូសូហ្វ (Microsoft) ទាំងហ្គូហ្គល (Google) សុទ្ធតែជឿជាក់លើការបើកចំហបច្ចេកវិទ្យាឲ្យ ទូលំទូលាយ និងការប្រកួតប្រជែង ហើយជឿថាបើបច្ចេកវិទ្យាណាមួយល្អជាង នោះវានឹងសុះសាយ លឿនជាងហើយ។ ប៉ុន្តែចបវិញមិនអញ្ចឹងទេ។ សំខាន់គឺមិនចង់ឲ្យនរណា

មកធ្វើដូចខ្លួន គឺដឹងតែចោទ ប្រកាន់គេឯងថាលួចគំនិតខ្លួន និងគោលគំនិតពីអេបផល។

មនុស្សប្រភេទចបជាមនុស្សដែលចូលចិត្តគ្រប់គ្រងត្រួតត្រាលើគេហួសប្រមាណ ដូច្នេះហើយសូម្បី តែផលិតផលខ្លួនក៏គាត់ខំប្រឹងការពារមិនឲ្យគេលួចចម្លងរបស់គាត់ដែរ ហើយក៏ព្យាយាមលាក់ របស់ខ្លួនខ្លាំងបំផុតដែរ។ ដល់ពេលមានគេធ្វើបានស្រដៀងលោក លោកក៏ខឹងសម្បារភ្លាម។ អញ្ចឹងហើយបានជាលោកចូលចិត្តប្ដឹងប្ដល់គេឯងហ្នឹងឯង។

តាមពិតទៅ ចបមិនត្រឹមតែប្រកួតឈ្លោះតែជាមួយអ្នកខាងក្រៅទេ តែក៏ឈ្លោះជេរប្រមាថបុគ្គលិកនៅ ខាងក្នុងក្រុមហ៊ុនអេបផលដែរ បើឃើញថានរណាម្នាក់មិនខ្វល់ពីសុក្រឹត្យភាព។ បើមិនត្រូវជេរហុយ ផ្សេងទេ ក៏ត្រូវដេញចេញនឹងកន្លែងដែរ។ បើគាត់យល់ថាបុគ្គលិកណាម្នាក់មិនមែនជាបុគ្គលិកកំពូល លំដាប់ A ទេ និងធ្វើការងារមិនបាន ៩០ម៉ោងក្នុងមួយអាទិត្យទេ គាត់មិនស្ដីមិនថាឲ្យទេ គឺគាត់ បណ្ដេញចេញពីក្រុមហ៊ុនភ្លាមៗតែម្ដង។ បើបុគ្គលិកគាត់ធ្វើមិនទាន់តាមការបញ្ជាទិញរបស់អតិថិជនទេ គាត់នឹងសំពងគ្រប់គ្នានៅក្នុងប្រជុំ និងស្រែកជេរគេពេញអង្គប្រជុំតែម្ដង។ ឥរិយាបថអាក្រក់សាហាវ បែបនេះ គឺដោយសារតែគាត់គិតតែពីចង់បានភាពល្អឥតខ្ចោះ ឬសុក្រិត្យភាពនិយមពេក។

# ១២
# ចបស្លាប់មុនការគ្រោងទុក ដោយសារតែចចេសមិនស្តាប់ និងចង់ធ្វើអ្វីដែល ប្លែកខុសពីភាពដដែលៗ

នៅឆ្នាំ ២០០៣ ស្ទីវចបបានដឹងថាខ្លួនមានជម្ងឺមហារីក ប៉ុន្តែគាត់មិនស្តាប់តាមដំបូន្មានរបស់ពេទ្យទេ តែគាត់ធ្វើតាមគំនិតខ្លួនគាត់វិញ គឺព្យាបាលតាមការចាក់ម្ជុលវិទ្យាសាស្ត្រ និងការតបអាហារ ញុំាតែបន្លែ។ ដូចយើងដឹងហើយថាស្ទីវចបមិនចូលចិត្តធ្វើអ្វីៗតាមទំនៀមទម្លាប់ ដដែល ចាស់គម្រិលទេ ជាពិសេសលើការបង្កើតឱស្សាញផលិតផលគាត់អញ្ចឹង គាត់ចូលចិត្តបង្កើតអ្វីដែលថ្មីៗ មិនចង់ធ្វើអ្វីៗដែលចាស់ៗ ដូចតែគេដូចតែឯងដដែលៗទេ។ គ្រូពេទ្យថាឲ្យគាត់ប្រញាប់វះកាត់ ប៉ុន្តែគាត់បដិសេដមកធ្វើតាមវិធីគាត់អស់រយៈពេល ៩ខែ។

ពេលវេលាចេះតែកន្លងផុតទៅ ជម្ងឺមហារីកក៏បានរីកដុះដាលខ្លាំងឡើង។ ទីបំផុត គាត់ក៏សម្រេចចិត្ត វះកាត់កោសិកាមហារីកងាប់ៗចោល។

ប៉ុន្តែជម្ងឺក៏បានធ្វើទុក្ខឡើងសារជាថ្មីនៅឆ្នាំ ២០០៨ ប៉ុន្តែគាត់នៅតែចចេសខំប្រឹងហូបតែផ្លែឈើ និងបន្លែដើម្បីព្យាបាលខ្លួនឯង។ ជាលទ្ធផលគាត់ស្រកទម្ងន់អស់ជិត ២០គីឡូ។

ក្រោយមក ចបក៏សម្រេចចិត្តតាមការលួងលោមបញ្ចុះបញ្ចូលឲ្យវះកាត់ដូរលំពែង ប៉ុន្តែសុខភាពគាត់ វាបានដល់ដំណាក់កាលដែលមិនអាចស្រោចស្រង់បានបាត់ទៅហើយ។

ទីបំផុតនៅឆ្នាំ ២០១១ ស្ទីវចបក៏បានលាចាកលោកទៅ មុនអាយុ ពីព្រោះបើគាត់ស្តាប់តាមវិជ្ជៈបញ្ញា របស់គ្រូពេទ្យ គាត់អាចនឹងរស់នៅបានយូរជាងនេះ។ គាត់បានបន្សល់ទុកកេរ្តិ៍មរតកដែលជាកំព្យូទ័រ បច្ចេកវិទ្យាដែលមានតម្លៃខ្ពស់បំផុតមួយនៅក្នុងពិភពលោក។ ទោះបីជាម៉ៃក្រូសូហ្វគូសត្រូវធំបង្អស់ របស់ចបបានប្រើយុទ្ធសាស្ត្របើកចំហជើងមេឃ ពោលគឺបើកចំហអាជ្ញាប័ណ្ណរបស់ខ្លួនលក់ឲ្យកំព្យូទ័រ ទាំងឡាយក្នុងលោក និងគ្រប់គ្រងលើឧស្សាហាកម្មកំព្យូទ័រពាសពេញពិភពលោកជាច្រើនឆ្នាំក៏ដោយ ក៏អេបផលរបស់ចបបានឡើងខ្ពស់ជាងក្រុមហ៊ុនម៉ៃក្រូសូហ្វ បើគិតពីតម្លៃរបស់ក្រុមហ៊ុនទាំងមូល។

# សារសំខាន់

“គិតផ្សេង” គឺជាពាក្យពីរម៉ាត់យ៉ាងខ្លីដែលសង្ខេបគោលជំនឿសំខាន់បំផុតរបស់ចប ដែលមាន ន័យថាគិតកុំឲ្យដដែលៗ គិតកុំឲ្យដូចគេ គិតឲ្យថ្មីស្រឡាង និងមិនធ្វើតាមប្រពៃណីដដែលៗឡើយ។

*ស្ទីវ ចប* *សង្ខេបនិងរៀបរៀងដោយអេបbookeyond*




1- អេប **bookeyond** មានសៀវភៅជាង ២៣០ក្បាលហើយ

2- ហើយតែងតែបញ្ចូលសៀវភៅថ្មីៗ 3+ ក្បាល រៀងរាល់សប្តាហ៍

3- ទិញក៏បាន ភ្ជាប់គម្រោងក៏បាន

| | |
|---|---|
| សូមចុចប៊ូតុងខាងស្តាំដើម្បីទាញយកអេប | ទាញអេប |
| សូមចុចប៊ូតុងខាងស្តាំដើម្បី join តេឡេក្រាមយើង | តេឡេក្រាម |